ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 02 / 2018
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨**

ភាសា ៖ **អង់គ្លេស និងខ្មែរ [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសំណើរបស់ មាស មុត សុំបង្គាប់ឱ្យសហព្រះរាជអាជ្ញាជាតិផ្តល់ឯកសារ ដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**
អាង ឧត្តម
Michael KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រ៊ីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត("ស.ច.ស") នៅក្នុងសំណុំរឿងនេះបាន ចុះបញ្ជីនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាជាតិ ("ស.ព.ជ") បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនយោងតាមវិធានផ្ទៃក្នុង ៦៦ ដោយស្នើសុំឱ្យ ស.ច.ស លើកលែងការចោទប្រកាន់លើ មាស មុត ដោយផ្អែកលើមូលដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ មាស មុត ឡើយ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ")[1]។

៣. នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៨ មេធាវីការពារក្តី មាស មុត ("មេធាវីការពារក្តី") បានដាក់សំណើសុំបង្គាប់ឱ្យ ស.ព.ជ ផ្តល់ឯកសារមួយចំនួនដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ ("សំណើ")[2]។

៤. នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨ សហព្រះរាជអាជ្ញា បានជូនដំណឹងការិយាល័យរបស់ខ្ញុំថា សហព្រះរាជអាជ្ញា មិនមានបំណងដាក់ចម្លើយតបទៅនឹងសំណើទេ[3]។

## II. សារណា

៥. មេធាវីការពារក្តី ស្នើសុំឱ្យ ស.ច.ស បង្គាប់ឱ្យ ស.ព.ជ ផ្តល់ឯកសារខាងក្រោមនេះដែល ស.ព.ជ បានរៀបចំដាក់ជូនអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នាជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋាន

---

[1] សំណុំរឿង ០០៣ ឯកសារ D256/6 *ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណីមាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧។

[2] សំណុំរឿង ០០៣ ឯកសារ D256/10 *សំណើរបស់ មាស មុត សុំបង្គាប់ឱ្យសហព្រះរាជអាជ្ញាជាតិផ្តល់ឯកសារដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ* ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៨។

[3] សំណុំរឿង ០០៣ ឯកសារ D256/10/1.1 *ឧបសម្ព័ន្ធ៖ អ៊ីមែលពី Nicholas Koumjian ផ្ញើជូន Nivedha Thiru* ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨។

ស្តាពររបស់ ស.ព.ជ ហើយអះអាងថាមានសំអាងហេតុរបស់ ស.ព.ជ គាំទ្រការយល់ឃើញរបស់គាត់ដែលថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ មាស មុត ឡើយ៖

ក. *ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីអង្គហេតុ និងសំអាងហេតុនៃការខ្វែងយោបល់គ្នា យោងតាមវិធានផ្ទៃក្នុង៧១.២ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៨*

ខ. *ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ ឱ្យផ្តល់ឯកសារពិស្តារបន្ថែម ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩* (“ឯកសារ”)[4]។

៦. មេធាវីការពារក្តី អះអាងថា ខ្លួនត្រូវការឯកសារទាំងនេះ ដើម្បីអាចដាក់ចម្លើយតបប្រកបដោយអត្ថន័យទៅនឹងដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ និងទឡ្ហីករណ៍របស់ ស.ព.អ ដែលបានលើកឡើងប្រឆាំងនឹង ស.ព.ជ។ មេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា ស.ព.អ ដឹងច្បាស់អំពីការយល់ឃើញរបស់ ស.ព.ជ អំពីយុត្តាធិការបុគ្គល ចំណែកឯ មេធាវីការពារក្តី មិនអាចចូលពិនិត្យមើលឯកសារបានឡើយ ដូច្នេះរំលោភបំពានសិទ្ធិការពារក្តីប្រកបដោយប្រសិទ្ធភាព និងសមភាពនៃការតទល់ក្តី[5]។

៧. ដោយហេតុថា ស.ព.ជ មិនបានឆ្លើយតបតាមសំណើសុំឯកសាររបស់ មេធាវីការពារក្តី[6] ទើបមេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា ឯកសារទាំងនេះអាចជាឯកសារសម្ងាត់ យោងតាមវិធានផ្ទៃក្នុង ៧១ ប៉ុន្តែ ដោយសារថា ឯកសារទាំងនេះត្រូវបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ ទើបឯកសារទាំងនេះត្រូវឱ្យដាក់បង្ហាញ[7]។

---

[4]សំណើ ទំព័រ ១ កថាខណ្ឌ ១-២ ដកស្រង់ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ កថាខណ្ឌ ៤,៦ និង ៨ ជើងទំព័រ ៤២-៤៣, ៤៧-៥៣ និង ៥៧-៦៣។

[5]សំណើ កថាខណ្ឌ ៧-១០។

[6]សំណើ ទំព័រ ១, ៥[ភាសាអង់គ្លេស] កថាខណ្ឌ ១១-១៤។

[7]សំណើ កថាខណ្ឌ ១៦។

## III. ពិភាក្សា

៨. ដូចបានបញ្ជាក់នៅក្នុងដីកាសម្រេចមួយនៅក្នុងសំណុំរឿង ០០៤/២ (ដែលបានបន្ថែមចូលក្នុងសំណុំរឿង ០០៣ រួចហើយ[8] ប៉ុន្តែ មេធាវីការពារក្តី មិនបានយោងលើទេនៅក្នុងសំណើ) ករណីខ្វែងយោបល់គ្នាណាមួយរវាងសហព្រះរាជអាជ្ញា គឺជាការសម្ងាត់ ហើយ ស.ច.ស មិនអាចចូលពិនិត្យមើលបានឡើយ ហើយក៏មិនមានអំណាចបង្គាប់ឱ្យសហព្រះរាជអាជ្ញា ដាក់បង្ហាញករណីខ្វែងយោបល់គ្នានេះបានដែរ[9]។ ឯកសារទាំងឡាយដែលបានរៀបចំឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីខ្វែងយោបល់គ្នានៅចំពោះមុខ អ.ប.ជ គឺស្ថិតនៅក្នុងដែនអំណាចផ្តាច់មុខរបស់ អ.ប.ជ ហើយ អ.ប.ជ ជាអ្នកសម្រេចថាតើឯកសារបែបនេះគួរដាក់បង្ហាញដែរឬអត់[10]។

៩. ត្រង់ចំណុចដែលសំណើពាក់ព័ន្ធនឹងការពិភាក្សាដេញដោលនៅរដ្ឋសភារបស់ប្រទេសកម្ពុជា អំពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងអំពីច្បាប់ អ.វ.ត.ក[11] នោះ គួររំឭកថា អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា ពាក្យថា "*មេដឹកនាំជាន់ខ្ពស់*" និង "*ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*" មិនមានការបកស្រាយដាច់ខាតឡើយ ហើយច្បាស់ណាស់ មិនមានន័យពាក់ព័ន្ធនឹងការកំណត់ចំនួនជនដែលត្រូវស៊ើបអង្កេត និងចោទប្រកាន់ឡើយ[12] ប៉ុន្តែ ពាក្យពេចន៍ទាំងនេះគ្រាន់តែមានបំណងធ្វើជាគោលការណ៍ណែនាំសម្រាប់ការស៊ើបអង្កេត និងការចោទប្រកាន់តែប៉ុណ្ណោះ[13]។ ស.ច.ស

---

[8] សំណុំរឿង ០០៣ ឯកសារ D262 *ដីកាសម្រេចដាក់សេចក្តីសម្រេចទាក់ទងនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣* ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ កថាខណ្ឌ ៦។

[9] សំណុំរឿង ០០៣ ឯកសារ D262.2 *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់* ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ("ដីកាសម្រេចសំណុំរឿង ០០៤/២") កថាខណ្ឌ ៧។

[10] ដីកាសម្រេចសំណុំរឿង ០០៤/២ កថាខណ្ឌ ៨។

[11] សំណើ កថាខណ្ឌ ១ ដកស្រង់ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ កថាខណ្ឌ ៦។

[12] សំណុំរឿង ០០៣ ឯកសារ D261 *ដីកាដំណោះស្រាយ (សំអាងហេតុ) សំណុំរឿង ០០៤/១* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ៣៧។

[13] សំណុំរឿង ០០១ ឯកសារ F28 *សាលដីកា* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦៣-៦៨, ៧៤-៧៧។

បានប្រកាន់យកសេចក្តីសម្រេចបែបនេះរួចហើយនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)នៃសំណុំរឿង 00៤/១[14]។

១០. ដើម្បីឱ្យយល់កាន់តែច្បាស់អំពីការពិភាក្សាដេញដោលរបស់អ្នករៀបចំកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក នៅក្នុងអំឡុងពេលចរចាគ្នានោះ គឺគួរតែអាចចូលពិនិត្យមើលប្រវត្តិទាំងស្រុងនៃការពិភាក្សាចរចាគ្នាសិន ប៉ុន្តែ មិន*ចាំបាច់* ទាល់តែធ្វើដូច្នេះឡើយ[15]។

១១. ចុងក្រោយ តាមខ្លឹមសារ សំណើ មានផ្នែកខ្លះជាសំណើសុំបំពេញកិច្ចស៊ើបសួរ ហើយសំណើបែបនេះគឺអស់ពេលហើយ។ កិច្ចស៊ើបសួរបានបិទបញ្ចប់ពីរដងរួចហើយ។ ពេលវេលាដែលអនុញ្ញាតឱ្យដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ទាប់ពីបិទកិច្ចស៊ើបសួរ គឺមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៦(១) ហើយប្រសិនបើទោះបីជាថាគេអនុវត្តតាមការយល់ឃើញនាពេលថ្មីៗនេះរបស់ អ.ប.ជ ប៉ុន្តែមិនមែនជាសេចក្តីសម្រេចតុលាការទេដែលថា ពេលវេលានេះត្រូវកំណត់ម្តងទៀតបន្ទាប់ពីបិទកិច្ចស៊ើបសួរនីមួយៗយ៉ាងណាក៏ដោយ[16] ក៏សំណើនៅតែបង្ហាញឱ្យឃើញថាអស់ពេលដែរ។ មេធាវីការពារក្តី មិនបានលើកឡើងពីទឡ្ហីករណ៍អំពីមូលហេតុដែលគួរមានករណីលើកលែងពីវិធាននោះទេ ជាពិសេសនៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី។ ផ្ទុយមកវិញ ការយោងលើឯកសារ និងការយោងលើអត្ថិភាពនៃករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល គឺមាននៅក្នុងសំណុំរឿងរួចហើយតាំងពីខែ វិច្ឆិកា ឆ្នាំ ២០១០ មកម្លេះ[17] ហើយសំអាងហេតុរបស់ ស.ព.ជ ត្រូវ

---

[14]ដីកាសម្រេចសំណុំរឿង 00៤/២ កថាខណ្ឌ ១២។ សំណុំរឿង 00៣ ឯកសារD261 *ដីកាដំណោះស្រាយ (សំអាងហេតុ) សំណុំរឿង 00៤/១* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ផ្នែក ២.១៖ យុត្តាធិការបុគ្គលនៅ អ.វ.ត.ក។

[15]សំណុំរឿង 00៣ ឯកសារ D181 *ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល* ថ្ងៃទី 0១ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ៣៣។

[16]សំណុំរឿង 00៤ ឯកសារ D361/4/1/10 *[កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់* ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ កថាខណ្ឌ ២៣-២៧។

[17]សំណុំរឿង 00៣ ឯកសារ D1/1.3 *ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ កថាខណ្ឌ ២,៥, ៩, ៣១-៣២ និង ៣៩។

ចៅក្រមជាតិនៅ អ.ប.ជ យោងលើជាច្រើនដងរួចហើយនៅគ្រប់សំណុំរឿងទាំងអស់ រួមមានសំណុំរឿង ០០៣ ផងដែរ[18]។

១២. ដីកាសម្រេចនេះអាចមានប្រយោជន៍ដល់ភាគីសំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ហើយខ្ញុំនឹងបង្គាប់ឱ្យដាក់សំណៅមួយច្បាប់ចូលក្នុងសំណុំរឿងទាំងនេះ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

១៣. **បដិសេធ**សំណើ។

១៤. **បង្គាប់ឲ្យ** ដាក់សំណៅមួយច្បាប់នៃដីកាសម្រេចនេះចូលក្នុងសំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២។

ភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

---

[18]សំណុំរឿង ០០៣ ឯកសារ D120/3/1/8 *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ មតិយោបល់របស់ចៅក្រមប្រាក់ គឹមសាន ចៅក្រមន័យ ថុល និង ចៅក្រមហ្ស៊ត វុទ្ធី កថាខណ្ឌ ២៧-២៨។ សំណុំរឿង ០០៣ ឯកសារ D165/2/26 *សាលដីការបស់អង្គបុរេជំនុំជម្រះ ១)លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ១៣៩។